# ១៤

## អតីត  អនាគត  និង បច្ចុប្បន្ន

ពាក្យ អតីត អនាគត និងបច្ចុប្បន្ន យើងសុទ្ធតែដឹងន័យទាំងអស់គ្នា ។ ការយល់ពាក្យបច្ចុប្បន្ន ក្នុងធម៌ព្រះពុទ្ធ គួរតែវែកញែកឲ្យច្បាស់ដែរ ។ ដូចជាពាក្យថា « យើងត្រូវរស់នៅក្នុងបច្ចុប្បន្ន » (Il faut vivre dans le présent) តើមានន័យយ៉ាងណាដែរ ?

មុនដំបូង ខ្ញុំសូមបញ្ជាក់នូវពាក្យដែលយើងប្រើ ដើម្បីប្រាប់កាលទាំងបី គឺ៖

- ចំពោះ អតីតកាល យើងប្រើពាក្យ « **បាន** » ឧទាហរណ៍ ធម៌ ដែលខ្ញុំបាន រៀន (ហើយ)។

- ចំពោះ អនាគតកាល យើងប្រើពាក្យ « **នឹង** » ឧទាហរណ៍ ធម៌ ដែលខ្ញុំនឹង រៀន (នៅថ្ងៃមុខ)។

- ចំពោះ បច្ចុប្បន្នកាល យើងប្រើពាក្យ « **កំពុងតែ** » ឧទាហរណ៍ ធម៌ ដែលខ្ញុំកំពុងតែ រៀន (នៅសព្វថ្ងៃនេះ ឬ នៅពេលនេះ) ។

ចុះពាក្យថា « យើងត្រូវរស់នៅក្នុងបច្ចុប្បន្ន » មានន័យដូចម្ដេច ?

មានន័យថា បើយើងកំពុងតែ ហូបបាយ សតិរបស់យើង ត្រូវនៅជាប់តែនឹងការហូបបាយ កុំគិតទៅអ្វីផ្សេងទៀត ដូចជា ហូបបាយផង ឆ្លៀតមើលសារពត៌មានផង ឬ មួយហូបបាយផង ហើយនឹកគិតទៅកិច្ចការដែលនឹងធ្វើនៅថ្ងៃស្អែកផង។ ពាក្យបារាំងថា កិច្ចការនីមួយៗ មានពេលសម្រាប់តែកិច្ចការនោះ (chaque chose en son temps) ។

ឧទាហរណ៍ កាលខ្ញុំនៅធ្វើការនៅឡើយ មានពេលមួយនោះកិច្ចការដែលខ្ញុំធ្វើ ខ្ញុំ ត្រូវធ្វើឲ្យហើយមុនថ្ងៃកំណត់ ដោយខ្ញុំដក់ទៅក្នុងកិច្ចការនោះខ្លាំងពេក ខ្ញុំចង់ភ្លេចហូបបាយទឹក ហើយដល់ទៅហូបបាយ នៅពេលកំពុងតែហូប ចិត្តខ្ញុំនៅតែគិតទៅកិច្ចការនោះ

ទៀត ដល់ហុតទឹកសម្លមិនបានប្រយ័ត្ន ក៏ហៀរប្រឡាក់ខោអាវ ។ ក្នុងឧទាហរណ៍នេះ ពេលបច្ចុប្បន្ន គឺ ពេលកំពុងហូបបាយ ក្រៅពីនោះគឺ ពេលអតីត ឬ ពេលអនាគត ។ ឧទាហរណ៍មួយទៀត បើនិយាយពីម៉ោង បើម៉ោង 12H05 ជាពេលបច្ចុប្បន្ន នោះម៉ោង 12H04 ជាពេលអតីត ហើយ ម៉ោង 12H06 ជាពេលអនាគត ។តាមការពិសោធន៍ បើកាលណាចិត្តយើងនៅមូលជាប់តែនឹងកិច្ចការដែលយើង **កំពុងតែធ្វើ** នោះលទ្ធផលបានមក ល្អហើយចំណាយពេលខ្លីទៀត តែបើចិត្តមិនមូលទេ លទ្ធផល មិនបានល្អ ហើយថែមទាំងចំណាយពេលច្រើនទៀតផង។ អ្នកខ្លះគេថា ៖ មួយថ្ងៃ ស្មើនឹងបីថ្ងៃ បើយើងធ្វើការអ្វីមួយ យើងធ្វើតែការនោះ ឬ គិតតែទៅលើការនោះ។ មានលោកគ្រូខ្លះ ពន្យល់ថា ដោយយើងត្រូវតែរស់នៅក្នុងពេលបច្ចុប្បន្ន ដូច្នេះយើងមិនត្រូវគិតអនាគតទេ ពីព្រោះអនាគតមិនទៀង ហើយក៏ពុំទាន់មកដល់ផង ។ ខ្ញុំសួរថា **បើដូច្នេះតើអ្វីៗដែលយើងនឹងធ្វើនៅពេលខាងមុខ នោះយើងអាចគិតទុកជាមុនបានទេ ដូចជាគំរោងការជាដើម?**

តាមខ្ញុំយល់ យើងត្រូវមាន សតិដោតជាប់ទៅនឹងកិច្ចការដែលយើង **កំពុងតែធ្វើ** ទោះជាកិច្ចការនោះមានប្រភេទបែបណាក៏ដោយ ឬជាកិច្ចការដែល**នឹងធ្វើនៅ**ថ្ងៃខាងមុខក៏ដោយ ។ ឧបមាថា មានកិច្ចការពីរ កិច្ចការទី១ គឺសរសេរសំបុត្រតបទៅនឹងសំបុត្រដែលទើបនឹងបានទទួល កិច្ចការទី២ គឺគិតអំពីការរៀបចំតុទទួលភ្ញៀវ ដោយត្រូវដាក់ភ្ញៀវដែលស្គាល់គ្នាឲ្យអង្គុយជិតគ្នា នៅពេលជប់លៀងនៅខែខាងមុខ ។ ក្នុងឧទាហរណ៍នេះ ថ្វីបើ ពេលជប់លៀងនៅមួយខែទៀតក៏ដោយ ខ្ញុំត្រូវតែគិតកិច្ចការទី២ មុនថ្ងៃជប់លៀង បើមិនដូច្នោះទេ ចាំដល់ពេលភ្ញៀវមកដល់បានគិត នោះគិតមិនទាន់ទេភ្ញៀវមុខជាឈរចាំរួយជើងស្លាប់ហើយ ។ ដូច្នេះត្រូវតែគិតទុកជាមុន គ្រាន់តែនៅពេលដែលខ្ញុំ <u>កំពុងតែ</u> សរសេរសំបុត្រ(ធ្វើកិច្ចការទី១) ខ្ញុំ<u>មិនត្រូវ</u> នឹកគិតទៅកិច្ចការទី២នោះទេ។

មានថ្ងៃមួយនោះ តាមទូរទស្សន៍ មានកីឡាកម្នាក់ដែលទើបនឹងបានជ័យជម្នះ ក្នុងការប្រកួតប្រជែង បានឆ្លើយទៅនឹងសំណួរអ្នកកាសែតថា « ឥឡូវខ្ញុំមិនគិតទៅថ្ងៃមុខទេ ខ្ញុំសូមសប្បាយនឹងជ័យជម្នះនេះសិនហើយ » ។ នេះ ដូចជាគេច្រើននិយាយថា រស់នៅក្នុងបច្ចុប្បន្ន មិនឲ្យខាតបង់ពេលនេះទេ ។ ពីព្រោះថាអ្វីៗ
សុទ្ធតែមិនទៀង ៖ រស់នៅក្នុងបច្ចុប្បន្ន ទាន់អាសន្នមិនទាន់មក ។